រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ

## រោងចក្រផលិតទឹកស្អាតថ្មី បាក់ខែង ជំហាន១ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** (**រ.ទ.ស.ភ**) មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនទាំងអស់ជ្រាបថា នាថ្ងៃចន្ទ ២កើត ខែបឋមសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** អញ្ជើញចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការរោងចក្រផលិតទឹកស្អាតថ្មី បាក់ខែង ជំហាន១ ដែលជាសមិទ្ធិផលដ៏ត្រចះត្រចង់មួយរបស់ រ.ទ.ស.ភ លាតសន្ធឹងលើផ្ទៃដី ១៥ហិកតា មានសមត្ថភាពផលិតទឹកស្អាតបានចំនួន ១៩៥.០០០ម$^{៣}$/ថ្ងៃ ដោយប្រើប្រាស់ប្រភពទឹកទន្លេមេគង្គលើក្នុងការផលិត ដែលមានទីតាំងនៅភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ (តាមបណ្តោយមហាវិថីឈ្នះឈ្នះ)។

គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែងជំហានទី១ គឺជាសហហិរញ្ញប្បទានរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា រ.ទ.ស.ភ ជាមួយនឹងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ធនាគារវិនិយោគអឺរ៉ុប (EIB) និងសហគមន៍អឺរ៉ុប (EU) ដោយប្រើប្រាស់ថវិកាសរុបចំនួន ២៤៧លាន ដុល្លារអាមេរិក ។

ការសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១ ចាប់ផ្តើមដំណើរការសាងសង់ពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ និងបានដាក់ដំណើរការសាកល្បងផលិត និងចែកចាយទឹកស្អាតចាប់ពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ ព្រមទាំងឈានដល់បញ្ចប់ការដ្ឋានសាងសង់ជាស្ថាពរនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ ពោលគឺមានរយៈពេលសាងសង់ចំនួន ៣៦ខែ។ រោងចក្រផលិតទឹកស្អាតបាក់ខែង ជំហាន១ គឺជាគម្រោងធំជាងគេជាប្រវត្តិសាស្ត្រក្នុងវិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតកម្ពុជា ដែលអនុវត្តការងារសាងសង់ដោយក្រុមហ៊ុន Vinci Construction Grands Projets មកពីប្រទេសបារាំង ស្ថិតក្រោមការត្រួតពិនិត្យរបស់ រ.ទ.ស.ភ និងការជួយផ្តល់យោបល់ពីទីប្រឹក្សាបច្ចេកទេស SAFEGE Consulting Engineers មកពីប្រទេសបារាំង។ សម្រាប់គម្រោងនេះ ត្រូវបានអនុវត្តកិច្ចសន្យាក្នុងក្របខ័ណ្ឌ រចនា និងប្លង់។

រោងចក្រផលិតទឹកស្អាតបាក់ខែងជំហាន១ មានសមត្ថភាពផលិតទឹកស្អាតចំនួន ១៩៥.០០០ម$^{៣}$/ថ្ងៃ បានបន្ថែមលើសមត្ថភាពផលិតទឹកស្អាតរបស់ រ.ទ.ស.ភ ដែលមានស្រាប់ចំនួន ៦៤០.០០០ម$^{៣}$/ថ្ងៃ នាំអោយ រ.ទ.ស.ភ មានសមត្ថភាពផលិត និងផ្គត់ផ្គង់ទឹកស្អាតសរុបបានប្រមាណ ៨៣៥.០០០ម$^{៣}$/ថ្ងៃ ព្រមទាំងបន្ថែមការផ្គត់ផ្គង់ជូនប្រជាពលរដ្ឋបានប្រមាណ ១៧០.០០០គ្រួសារ និងជួយដោះស្រាយបញ្ហាទឹកស្អាតរបស់ប្រជាជនរស់នៅតំបន់ជាយរាជធានីភ្នំពេញ និងសង្កាត់ចំនួន០៣ នៅក្រុងតាខ្មៅ។



អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ:(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

នៅដើមឆ្នាំ២០២៤ ក្រោយដាក់ដំណើរការរោងចក្រផលិតទឹកស្អាតបាក់ខែង ដំហាន២ រ.ទ.ស.ភ និងមានសមត្ថភាពផលិត និងផ្គត់ផ្គង់ទឹកស្អាតសរុបកើនដល់ប្រមាណជាង ១លាន ម៉ែត្រគូបក្នុងមួយថ្ងៃ។ ការណ៍នេះធ្វើអោយប្រជាពលរដ្ឋដែលរស់នៅជាយរាជធានីភ្នំពេញ ទទួលបានការផ្គត់ផ្គង់ទឹកស្អាតដែលធានាបាននូវសម្ពាធទឹកល្អប្រសើរ ព្រមទាំងបានបិទបញ្ចប់នូវនិន្នាការកង្វះខាតទឹកស្អាតក្នុងពេលបច្ចុប្បន្ន ត្រឹមដើមឆ្នាំ២០២៤។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទាំងអស់ទទួលជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ២ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០២៣

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**



អគារ ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh